**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**លេខ** ២៣០៩ **សហវ.** ទវ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៩៣៩.៤៧៩.៩២ ដុល្លារអាមេរិក សម្រាប់ធ្វើការកែលម្អសំណង់ធារាសាស្ត្រក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រអាងត្រពាំងថ្ម ក្រោមឥណទានកម្មវិធី ADB 2022-CAM(SF) ។

**យោង:** លិខិតលេខ ២៨៦ ធទឧ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ៩៣៩.០០០ ដុល្លារអាមេរិក (ប្រាំបួនរយសាមសិបប្រាំបួនពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ធ្វើការកែលម្អសំណង់ធារាសាស្ត្រក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រអាងត្រពាំងថ្ម ស្ថិតក្នុងស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2585-CAM(SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ
- ឯកសារ-កាលប្បវត្តិ